ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៩១៨៦ អពដ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សហគ្រាសជាអ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ និងសហគ្រាសពាក់ព័ន្ធ មេត្តាជ្រាបថា ថ្មីៗនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៥៥៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ដែលនៅក្នុងប្រកាសនោះ មានការកំណត់និយមន័យនៃពាក្យមួយចំនួន រួមទាំងពាក្យ "សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ" ហើយត្រូវបានអង្គភាពឯកជន និងសារព័ត៌មានមួយចំនួនយកទៅបកស្រាយពុំបានត្រឹមត្រូវ នាំឱ្យមានការភ័ន្តច្រឡំពីសំណាក់សាធារណជនថា រាជរដ្ឋាភិបាលទើបនឹងអនុវត្តអាករលើតម្លៃបន្ថែមទៅលើសេវាហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានពន្ធដារសូមបញ្ជាក់ជូនថា អាករលើតម្លៃបន្ថែមត្រូវបានដាក់អនុវត្តតាំងពីឆ្នាំ ១៩៩៩ មកម្ល៉េះ។ មាត្រា៥៧ នៃច្បាប់ស្តីពីសារពើពន្ធ បានចែងអំពីការផ្គត់ផ្គង់មិនជាប់អាករ ដែលក្នុងនោះមានសេវាមួយចំនួន រួមទាំងសេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុផងដែរ។ ដូចនេះ ការចេញប្រកាសលេខ ៥៥៩ សហវ.ប្រក គឺគ្រាន់តែកំណត់ឱ្យបានច្បាស់លាស់នូវនិយមន័យនៃសេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដើម្បីពង្រឹងសង្គតិភាពក្នុងការអនុវត្តអាករលើតម្លៃបន្ថែមតែប៉ុណ្ណោះ មិនមែនជាការបង្កើតឬដាក់ឱ្យអនុវត្តពន្ធថ្មីនោះទេ។ លើសពីនេះទៅទៀត ការដាក់ចេញនូវប្រកាសនេះ គឺអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានបន្ថែមការលើកលែងអាករលើតម្លៃបន្ថែមសម្រាប់មុខទំនិញ និងសេវាមួយចំនួនថែមទៀត ដើម្បីជួយសម្រួលដល់តម្រូវការចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា សហគ្រាសជាអ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ និងសហគ្រាសពាក់ព័ន្ធ នឹងចូលរួមសហការអនុវត្តយ៉ាងយកចិត្តទុកដាក់ប្រកបដោយប្រសិទ្ធភាពខ្ពស់ ហើយសារព័ត៌មាននានាដែលធ្វើការផ្សព្វផ្សាយមិនបានត្រឹមត្រូវគប្បីធ្វើការកែតម្រូវឱ្យបានសមស្របតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ។

អគ្គនាយកដ្ឋានពន្ធដារ